ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ផលិតកម្មដំណាំស្រូវនិងការបន្សុាំការប្រែប្រួលអាកាសធាតុ







ភ្នំពេញ ខែ ឧសភា ឆ្នាំ ២០១៧

IFAD
Investing in rural people

រៀបចំដោយ : កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ( ASPIRE)
ឧបត្ថម្ភដោយ : រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម(IFAD)

# មាតិកា

មាតិកា .......... 2

សេចក្តីថ្លែងអំណរគុណ .......... 3

មេរៀនទី ១: ការជ្រើសរើសគ្រាប់ពូជ .......... 4

មេរៀនទី ២: ការរៀបចំពូជសម្រាប់ដាំដុះ .......... 7

មេរៀនទី ៣: ការរៀបចំថ្នាលសំណាប .......... 10

មេរៀនទី ៤: ការរៀបចំដី និងការដាក់ជីទ្រាប់បាត .......... 12

មេរៀនទី ៥: បច្ចេកទេសដាំដុះ .......... 15

មេរៀនទី ៦: ការគ្រប់គ្រង និងថែទាំ .......... 18

មេរៀនទី ៧: ការប្រមូលផល និងការទុកដាក់គ្រាប់ស្រូវ .......... 22

មេរៀនទី៨: ការបញ្ចូលរបៀបថ្មី លើគោលគំនិត អាជីវកម្មកសិកម្មខ្នាតតូច ផ្នែកផលិតកម្មដំណាំស្រូវ .......... 24

ឯកសារយោង .......... 30

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម (IFAD) ដែលបានផ្តល់ហិរញ្ញប្បទានដល់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីអនុវត្តកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់របស់គ្រួសារកសិករខ្នាតតូចក្រីក្រនិងងាយរងគ្រោះនៅកម្ពុជា។ កម្មវិធីបានផ្តល់ថវិកាដល់អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្មដើម្បីអនុវត្តសមាសភាពទី២នៃកម្មវិធី គឺការអភិវឌ្ឍសមត្ថភាពសេវាផ្សព្វផ្សាយកសិកម្ម ក្នុងគោលបំណងជួយគាំទ្រការកែលម្អសេវាផ្សព្វផ្សាយ កសិកម្មនៅថ្នាក់ក្រោមជាតិនិងថ្នាក់មូលដ្ឋាន តាមរយៈការបង្កើនគុណភាពផ្សព្វផ្សាយកសិកម្ម ការគ្រប់គ្រងចំណេះដឹង និងការពង្រឹងធនធានមនុស្សសម្រាប់ការងារផ្សព្វផ្សាយកសិកម្ម។

បម្រែបម្រួលអាកាសធាតុ មានការប្រែប្រួលខ្លាំងនៃរដូវកាលដែលបានផ្លាស់ប្តូរ ហើយបង្កឲ្យមានផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់កសិករ និងផលប៉ះពាល់ដល់មុខរបរកសិកម្មដែលធ្វើឱ្យទទួលបានប្រាក់ចំណូលទាប ដូច្នេះហើយទើបកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុរៀបចំឯកសារផ្តល់ចំណេះដឹងនេះឡើងដើម្បីឆ្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុឲ្យបានទាន់ពេលវេលា ដែលជាតម្រូវការរបស់កសិករខ្នាតតូចគ្រប់ៗគ្នាទាំងក្នុងនិងក្រៅគម្រោងផងដែរ។

យើងសង្ឃឹមថាឯកសារនេះនឹងជួយដល់មន្ត្រីផ្សព្វផ្សាយនិងភ្នាក់ងារផ្សព្វផ្សាយ ដើម្បីបង្ហាត់បង្ហាញអំពីបច្ចេកទេសផលិតកម្មដំណាំស្រូវក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ជាវិធីសាស្ត្រងាយៗនិងសាមញ្ញនៅក្នុងផលិតកម្មដំណាំស្រូវ ដែលកសិករអាចធ្វើបាននិងទទួលប្រាក់ចំណូលកើនឡើង។ ឯកសារណែនាំ "**ផលិតកម្មដំណាំស្រូវ និងការបន្សាំការប្រែប្រួលអាកាសធាតុ**" នេះគឺជាសមិទ្ធផលថ្មីមួយរបស់កម្មវិធី ASPIRE ដែលភាពជោគជ័យក្នុងដំណើរការរៀបចំសៀវភៅនេះ គឺអាស្រ័យទាំងស្រុងទៅលើកិច្ចសហប្រតិបត្តិការ និងការចូលរួមនៃក្រុមការងារបច្ចេកទេសរបស់កម្មវិធី នៃអគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

# មេរៀនទី ១: ការជ្រើសរើសគ្រាប់ពូជ

## ១.គោលបំណង ឲ្យកសិករចេះ៖

- ❖ ជ្រើសរើសពូជត្រឹមត្រូវ សមស្របតាមលក្ខខណ្ឌភូមិសាស្ត្រ (ប្រព័ន្ធកៀរត្របរិស្ថាននៃដំណាំស្រូវ) សេដ្ឋកិច្ចគ្រួសារ តម្រូវការទីផ្សារ និងធន់ទៅនឹងអាកាសធាតុប្រែប្រួល រាំងស្ងួត ឬទឹកជំនន់។

## ២. ការជ្រើសរើសគ្រាប់ពូជ

- ពូជផ្តល់ទិន្នផលខ្ពស់មានក្លិនក្រអូប
- គ្រាប់ពូជសុទ្ធមានគុណភាព (ដំណុះគ្រាប់ពី ៨៥% ឡើងទៅ)
- រយៈពេលលូតលាស់ (ស្រូវស្រាល ឬស្រូវកណ្តាល)
- ពូជធន់ទ្រាំទៅនឹងការរាំងស្ងួត សត្វល្អិតចង្រៃ និងជម្ងឺ
- គុណភាពគ្រាប់អង្ករ និងរសជាតិ។

**ក. ផ្អែកលើអាយុកាលដាំដុះពូជស្រូវចែកជា៣ក្រុម៖**

- ❖ ពូជស្រូវស្រាល ពូជស្រូវកណ្តាល ពូជស្រូវធ្ងន់

**ខ. ផ្អែកលើរយៈពន្លឺរបស់ថ្ងៃពូជស្រូវចែកជា២ក្រុម៖**

❖ **ពូជមិនប្រកាន់រដូវ:**

- ដាំបានគ្រប់រដូវកាលដាំដុះ រដូវប្រាំងនិងវស្សា ការប្រែប្រួលអាយុកាលដាំដុះតិចតួច
- ពូជស្រូវស្រាល អាយុកាលពីដាំដល់ប្រមូលផល ចន្លោះពី៩០ ទៅ១១០ថ្ងៃ
  - ពូជសែនពិដោរ ពូជជលសា ពូជអ៊ីអ៊ែ៦៦ ជាដើម។ល។



ពូជស្រូវជលសារ




ពូជស្រូវ សែនពិដោរ




ពូជស្រូវ អ៊ីអ៊ែរ៦៦



ពូជស្រូវផ្ការំដួល

- **ពូជប្រកាន់រដូវៈ**
  - ពូជដាំបានតែម្តងក្នុងមួយឆ្នាំ នៅរដូវវស្សា
  - ពូជស្រូវកណ្តាលនិងស្រូវធ្ងន់ ដាំដុះពីខែមេសាដល់កក្កដា និងប្រមូលផលចាប់ពីពាក់កណ្តាលខែវិច្ឆិកា ដល់ចុងខែមករា ឬខែកុម្ភៈ។

**គ. ផ្អែកលើក្លិនពូជស្រូវចែកជា២ក្រុមៈ**

- **ពូជក្រអូបៈ**
  - ពូជមានក្លិនប្រហើរ ទាំងដងដើមនិងបាយពេលចម្អិន
  - **ពូជស្រូវស្រាល និងស្រូវកណ្តាលៈ** ពូជសែនពិដោរ ពូជផ្ការំដួល ពូជផ្ការំដេង ជាដើម។ល។ ពូជខ្លះមានក្លិនក្រអូបប្រហើរខ្លាំង និងខ្លះមានក្លិនក្រអូបប្រហើរស្រាល។
- **ពូជមិនក្រអូបៈ**
  - ពូជមិនមានក្លិនប្រហើរ ទាំងដើមដង និងបាយពេលចម្អិន
  - ពូជស្រូវស្រាល ស្រូវកណ្តាល និងស្រូវធ្ងន់

- **ពូជស្រូវស្រាលៈ** ពូជផលសា ពូជអ៊ីអ៊ែ៦៦ ពូជខា១៤។ល។
- **ពូជស្រូវកណ្តាលៈ** ពូជផ្កាច័ន្ទសែនសរ ពូជខា១ ពូជខា២ ។ល។
- **ពូជស្រូវធ្ងន់ៈ** ពូជរាំងជ័យ ពូជខា៤ ពូជខា៦ ។ល។



ពូជស្រូវរាំងជ័យ



ពូជស្រូវខា១៤

# មេរៀនទី ២: ការរៀបចំពូជសម្រាប់ដាំដុះ

**១.គោលបំណង** ឲ្យកសិករចេះ៖

- ធ្វើដំណុះសាកគ្រាប់ពូជមុននិងយកទៅសាប
- បរិមាណគ្រាប់ពូជសម្រាប់ស្ទូង និងព្រោះ
- បច្ចេកទេសនៃការត្រាំនិងផ្អាប់គ្រាប់ពូជមុនដាំ ។

## ២. ការធ្វើដំណុះសាក

- យកគ្រាប់ដោយចៃដន្យ ៣កន្លែង ពីបាវស្រូវនីមួយៗ ខាងលើ កណ្តាល និងផ្នែកក្រោម នៃបាវ
- ច្របល់បញ្ចូលគ្នា ចាប់យក ១០០គ្រាប់ទាំងគ្រាប់ល្អ និងមិនល្អ អនុវត្ត៣សំណាក
- ដាក់គ្រាប់ស្រូវរាប់រួចក្នុងកែវ ឬចាន ចាក់ទឹកចូល ដល់លិច ពីលើគ្រាប់ពូជ ៣ស.ម កូរគ្រាប់ពូជឲ្យ សព្វគ្របទុកកន្លែងសុវត្ថិភាព
- ៣ ថ្ងៃក្រោយ រាប់ចំនួនគ្រាប់ដុះ និងមិនដុះ ចំនួនគ្រាប់ដុះសរុប ជាអត្រាដំណុះគ្រាប់ពូជ
- ដំណុះគ្រាប់ពូជឲ្យបាន ៨៥%គ្រាប់ដុះ។



គ្រាប់ពូជមិនល្អ និងដំណុះគ្រាប់



គ្រាប់ពូជល្អ និងដំណុះគ្រាប់

## ២. ការសំអាតគ្រាប់ពូជ




ការសំអាតគ្រាប់ពូជ

- គ្រាប់ពូជដំណុះទាប លាយសំដីច្រើន(គ្រាប់ស្បៀត)
- ចាក់គ្រាប់ពូជចូលក្នុងធុង ចាក់ទឹកចូលជិតពេញធុង
- កូរឲ្យសព្វ ស្រង់យកគ្រាប់អណ្តែតលើផ្ទៃទឹកចេញ
- គ្រាប់លិចក្នុងទឹកចាក់ទុកមួយកន្លែង
- បន្តធ្វើដល់អស់គ្រាប់ពូជ ដែលត្រូវយកទៅសាប។

### ❖ វិធីសាស្ត្រសំអាតគ្រាប់ពូជប្រើប្រាស់ល្បាយទឹកអំបិល៖

- ដាក់ស៊ុតមាន់ ឬស៊ុតទាល្អ ក្នុងធុងដាក់ទឹក (២ភាគ ៣)
- ចាក់អំបិលមួយចំនួនក្នុងទឹក កូរឲ្យរលាយ បន្តចាក់រហូតដល់ស៊ុតអណ្តែតលើផ្ទៃទឹក
- ចាក់គ្រាប់ពូជពាក់កណ្តាលធុង កូរឲ្យសព្វ កៀរយកសំដី គ្រាប់ស្មៅ យកគ្រាប់ស្រូវដែលអណ្តែតចេញ
- ស្រង់គ្រាប់លិចក្នុងធុងទុកមួយកន្លែង ធ្វើសរើសរហូតអស់គ្រាប់ពូជដែលត្រូវយកទៅសាប
- គ្រាប់ពូជប្រឡាក់ជាតិអំបិល លាងទឹកឲ្យស្អាតមុនយកទៅត្រាំ ការពារមិនឲ្យប៉ះពាល់ដំណុះគ្រាប់។



១ ២ ៣ ៤

វិធីសាស្ត្រប្រើប្រាស់ល្បាយទឹកអំបិល

## ៣. ត្រៀមបរិមាណពូជដែលត្រូវការសម្រាប់ដាំ

គ្រាប់ពូជដុះបានពី៨៥ %ឡើងប្រើក្នុងមួយហិកតា:

- ២០គីឡូក្រាម សម្រាប់ស្រូវសន្ទូង
- ៨០គីឡូក្រាម សម្រាប់ស្រូវពង្រោះ (ស្រូវប្រកាន់រដូវ)
- ១២០គីឡូក្រាម សម្រាប់ស្រូវស្រាលពង្រោះមិនប្រកាន់រដូវ
- ការថយចុះនៃអត្រាដំណុះគ្រាប់ពូជ ៥% ត្រូវបង្កើនគ្រាប់ពូជសម្រាប់ដាំដុះចន្លោះពី ៥ ទៅ១០គ.ក្រ ក្នុងផ្ទៃដីមួយហិកតា ឬច្រើនជាងនេះ។

## ៤. ការត្រាំនិងផ្អាប់គ្រាប់ពូជមុនដាំ

- បណ្តុះគ្រាប់ពូជមុនដោយច្រកគ្រាប់ ដែលសម្រិតសម្រាំងក្នុងបាវ ឬថង់ក្រណាត់ ត្រាំទឹក២៤ម៉ោង ស្រង់មកផ្អាប់ (ទាំងបាវ) ២៤ម៉ោង
- យកបាវក្រចៅ ឬចំបើងគ្របពីលើដើម្បីបង្កើនកំដៅ ឲ្យស្រូវពូជដុះលូតលាស់ល្អ
- លើកត្រឡប់បាវស្រូវពីលើចុះក្រោម ក្នុង១២ម៉ោងម្តង និងស្រោចទឹកផ្សើមតិចៗ ជាប្រចាំ។

## ៥. គុណសម្បត្តិនៃការប្រើប្រាស់ពូជសុទ្ធគុណភាពល្អ

- មានសារធាតុបម្រុង គ្រប់គ្រាន់ សំណាបលូតលាស់ និងមានសុខភាពល្អ
- ដើមស្រូវដុះលូតលាស់បានស្មើគ្នា
- កើនទិន្នផលពី ១៥% ទៅ ២០%
- ងាយលក់នៅទីផ្សារ ឬរោងម៉ាស៊ីនកិនស្រូវ មានតម្លៃល្អជាងស្រូវដែលមិនសុទ្ធ
- អត្រាអង្ករមានកម្រិតខ្ពស់ពេលកិន
- គុណភាពអង្ករល្អសមស្របទៅនឹងតម្រូវការទីផ្សារ មានតម្លៃខ្ពស់។



ពូជសុទ្ធ ស្រូវដុះលូតលាស់ល្អ



គុណភាពអង្ករល្អ

# មេរៀនទី ៣: ការរៀបចំថ្នាលសំណាប

## ១.គោលបំណង ឲ្យកសិករចេះ៖

- ជ្រើសរើសនិងរៀបចំទីកន្លែងសម្រាប់សាបសំណាប
- បច្ចេកទេសនៃការធ្វើថ្នាលសំណាប និងការថែទាំសំណាបឲ្យបានល្អ ។

## ២.ការជ្រើសរើសនិងរៀបចំទីកន្លែងសម្រាប់សាប

- ងាយស្រួល បញ្ចេញបញ្ចូលទឹក (ពេលរាំងស្ងួត ឬទឹកជំនន់)  ការពារសត្វពាហនៈ និងបក្សី
- ដីថ្នាលមានជីជាតិល្អ (ដងដើមមានសុខភាពល្អ អាចធន់ទ្រាំ និងគ្រោះរាំងស្ងួតរយៈពេលខ្លី)
- ឆ្ងាយពីម្លប់រុក្ខជាតិ ពីស្រែធ្វើថ្នាលពូជផ្សេងគ្នា ឬខ័ណ្ឌចែកដាច់ដោយភ្លឺ
- ផ្ទៃដីសាបសំណាប ៤០០ម៉ែត្រការ៉េ ឬ៤អា គ្រាប់ពូជ២០គីឡូសម្រាប់សាប និងស្ទូង លើផ្ទៃដី១ហិកតា។

## ៣.ការធ្វើថ្នាលសំណាប

### ក.ថ្នាលគោក

- បំផុសដីឲ្យហ្មត់រួច ហាលថ្ងៃ ៧-១០ថ្ងៃ សំអាតស្មៅ ពង្រាបដីរាបស្មើល្អ
- ជីកំប៉ុស្ត ២០០គីឡូក្រាម លាយផេះអង្កាម ១០០គីឡូ សម្រាប់ថ្នាល១០០ម៉ែត្រការ៉េ
- ទីតាំងក្បែរប្រភពទឹក ពន្លឺថ្ងៃគ្រប់គ្រាន់ រងទទឹង១ម៉ែត្រ ទៅ១,២ម៉ែត្រ
- គ្រាប់ពូជសាប០,១គីឡូក្រាម (១ខាំ) សម្រាប់ថ្នាលទំហំ១ម៉ែត្រការ៉េ





ការរៀបចំថ្នាលគោក

- ស្ទូងលើដី១ហិកតា សាបពូជ២០គីឡូក្រាម ថ្នាលសំណាប ២០០ម៉ែត្រការ៉េ ។

## ខ.ថ្នាលដាប៉ុក

- ល្បាយដី៖ ដី៥០% ជីកំប៉ុស្ត៣០% ផេះអង្កាម ២០% លាយឲ្យសព្វល្អ
- ដាក់បន្ទះឫស្សី៣ ស.ម សងខាងការពារដី គ្រាប់ពូជហូរចេញពីថ្នាល
- ក្រាលប្លាស្ទិក ឬស្លឹកឈើទ្រាប់បាតក្រោមរង កំពស់ ៥-៧សម
- ថ្នាលទទឹង ១ម៉ែត្រ បណ្តោយតាមតម្រូវការ
- ចាក់ល្បាយដី បានលាយច្របល់លើផ្ទៃថ្នាល កម្ពស់ ៣ ស.ម កៀរពង្រាបស្មើល្អ
- ប្រើពូជសាប ក្នុង១ម៉ែត្រការ៉េ ០,៥គីឡូក្រាម
- សាបរយៈពេល ៧ទៅ១០ថ្ងៃ ទើបដកយកទៅស្ទូង
- ស្ទូងលើដី១ហិកតា សាបពូជ២០គីឡូក្រាម លើថ្នាលសំណាប ២០០ម៉ែត្រការ៉េ ។

## ៤. ការថែទាំសំណាប

- ស្រោចទឹកជាប្រចាំ ១ថ្ងៃ ២ដង (ព្រឹកម្តង ល្ងាចម្តង) ស្រោចឲ្យសើមល្មម
- សំណាញ់ហាបាព័ទ្ធជុំវិញរងការពារសត្វ
- ពិនិត្យជាប្រចាំសត្វល្អិតស៊ីបំផ្លាញដំណាំស្រូវ រហូតដល់ដកយកទៅស្ទូង។


រៀបចំថ្នាល និងគ្របកៅស៊ូលើថ្នាល


ចាក់ល្បាយដីបំពេញថ្នាល


សាបគ្រាប់ពូជ រោយផេះអង្កាម និងពង្រាបថ្នាល


ការស្រោចទឹក


ថ្នាលសំណាបដាប៉ុក


សន្ទូងដុះលូតលាស់ល្អ

# មេរៀនទី ៤: ការរៀបចំដី និងការដាក់ជីទ្រាប់បាត

**១.គោលបំណង** ឲ្យកសិករចេះ៖

- បច្ចេកទេសរៀបចំដីសម្រាប់ស្ទូង សម្រាប់ដាំ ឬព្រោះ
- អត្ថប្រយោជន៍នៃការដាក់ជីទ្រាប់បាត ការភ្ជួរលប់គល់ជញ្ជ្រាំង
- ការបង្កើនសារធាតុចិញ្ចឹម (អាសូត) នៅក្នុងដី និងបង្កើតឲ្យមានអតិសុខុមប្រាណ និងបង្កើនឲ្យដីធូរ

## ២. ការរៀបចំដីសម្រាប់ស្ទូង

### ❖ ភ្ជួរលើកទី១

- ភ្ជួរចាប់ពីខែ កក្កដា ដល់សីហា ។ ភ្ជួរជម្រៅយ៉ាងតិច ១៥ស.ម រាស់ពង្រាបឲ្យបានស្មើល្អ ដើម្បី៖
    - កប់បញ្ចូលស្មៅ កាកសំណល់រុក្ខជាតិផ្សេងៗទៅក្នុងដីឲ្យរលួយ ក្លាយជាជីសម្រាប់ដំណាំស្រូវ
    - ងាយស្រួលគ្រប់គ្រងទឹក ជួយហាលដី ឲ្យស្ងួត បង្កើតឲ្យមានជីជាតិ និងខ្យល់ចេញចូល
    - លាយច្របល់ ឬកប់បញ្ចូលជីធម្មជាតិទៅក្នុងដី បង្កើតឲ្យមានអតិសុខុមប្រាណ និងបង្កើនឲ្យដីធូរ
    - បង្កើនសុខភាពប្រព័ន្ធឫសស្រូវ ជួយកំចាត់ការលូតលាស់ស្មៅចង្រៃ។




ភ្ជួរដីជម្រៅយ៉ាងតិច ១៥ សង្ទីម៉ែត្រ



លាយច្របល់ ឬកប់បញ្ចូលជីធម្មជាតិទៅក្នុងដី

### ❖ ភ្ជួរលើកទី២

- បន្ទាប់ពីភ្ជួរលើកទី១ ពី១២ទៅ១៥ថ្ងៃ
- មុនភ្ជួរបាចជីទ្រាប់បាតជាមុន រួចភ្ជួរ រាស់ និងកៀរដីស្រែឱ្យរាបស្មើល្អមុនស្ទូង
- ជីទ្រាប់បាត ដេ-អា-ប៉េ (DAP: 18-46-0) ៧៥គ.ក្រ និងជីប៉ូតាស្យូម (KCL: 0-0-60) ២៥គ.ក្រ ផ្ទៃដីមួយហិកតា ។




**ជី ដេ អា ប៉េ**
៧៥គីឡូក្រាម




**ជី ប៉ូតាស្យូម**
២៥គីឡូក្រាម



ការរៀបចំដីស្រែបានរាបស្មើល្អ



ការរៀបចំដីស្រែមិនបានរាបស្មើល្អ

## ៣. ការរៀបចំដីសម្រាប់ដាំ ឬព្រោះ ធ្វើឡើងយ៉ាងហោចណាស់ឱ្យបាន២ដង

### ❖ ភ្ជួរលើកទី១

- ដើមរដូវវស្សា ពីខែមេសា និងខែ ឧសភា
- ភ្ជួរឱ្យជ្រៅ ត្រឡប់ដីពីក្រោមឡើងលើ លប់កប់ជីធម្មជាតិដែលបានដាក់
- ភ្ជួរជម្រៅយ៉ាងតិច ១៥ស.ម រាស់ពង្រាបឲ្យស្មើល្អដើម្បី៖

- កប់បញ្ចូលស្មៅ និងកាកសំណល់រុក្ខជាតិផ្សេងៗទៅក្នុងដីឲ្យរលួយ ក្លាយជាជីសម្រាប់ដំណាំស្រូវ
- ងាយស្រួលក្នុងការគ្រប់គ្រងទឹក
- ជួយហាលដី ឲ្យស្ងួត បង្កើតឲ្យមានជីជាតិ និងខ្យល់ចេញចូល
- លាយច្របល់ ឬកប់បញ្ចូលជីធម្មជាតិទៅក្នុងដី បង្កើតឲ្យមានអតិសុខុមប្រាណ និងបង្កើនឲ្យដីធូរ
- បង្កើនសុខភាពប្រព័ន្ធឫសស្រូវ ជួយកំចាត់ការលូតលាស់របស់ស្មៅចង្រៃ។

## ❖ ភ្ជួរលើកទី២

- បន្ទាប់ពីភ្ជួរលើកទី១ បាន១២ទៅ១៥ថ្ងៃ
- មុនភ្ជួរលើកទី២ ត្រូវបាចជីទ្រាប់បាតជាមុន រួចភ្ជួររាស់ និងកៀរដីស្រែឱ្យបានស្មើល្អដើម្បីលប់ជី
- ជីទ្រាប់បាត ដេ-អា-ប៉េ (DAP: 18-46-0) ៧៥គ.ក្រ និងជីប៉ូតាស្យូម (KCL: 0-0-60) ២៥គ.ក្រ ផ្ទៃដីមួយហិកតា។
- ព្រោះគ្រាប់ពូជស្ងួត។




**ជី ដេ អា ប៉េ**
៧៥គីឡូក្រាម




**ជី ប៉ូតាស្យូម**
២៥គីឡូក្រាម



រាស់ និងកៀរដីស្មើល្អសម្រាប់ព្រោះ

# មេរៀនទី ៥: បច្ចេកទេសដាំដុះ

**១.គោលបំណង** ឲ្យកសិករដឹងពី បច្ចេកទេសដាំស្រូវមាន៖

- ដាំតាមពាក់កណ្តាលស្វ័យប្រវត្តិ
- ស្ទូងដោយដៃ ដែលមានដាក់ខ្សែជាបន្ទាត់ និងព្រោះគ្រាប់ស្ងួត
- ការដាំដោយម៉ាស៊ីន

## ២. ការស្ទូង

### ❖ អាយុសំណាប

- អាយុកាលស្រូវដកយកទៅស្ទូង ១៥-២០ថ្ងៃ
- ស្ទូងតាមវិធី ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ (ប-វ-ស SRI) អាយុពី ១២-១៥ថ្ងៃ គ្រប់ប្រភេទស្រូវ។

### ❖ ការដកនិងជ្រើសរើសសំណាបសម្រាប់ស្ទូង

- សំណាបមានសុខភាពល្អ ថ្លោស មិនមានសត្វល្អិតឬជម្ងឺ
- ដកថ្នមៗមិនឱ្យបាក់ដើមសំណាប ធ្វើឱ្យអត្រាដុះថយចុះ ឬដុះយឺតពេលស្ទូងរួច
- ដកភ្លាមស្ទូងភ្លាម ឬផ្អាប់គល់សំណាបតែមួយយប់។





ជ្រើសរើស និងដក សំណាបសុខភាពសម្រាប់ស្ទូងល្អ

### ❖ របៀបស្ទូង និងចន្លោះគុម្ពសន្ទូង

- ស្ទូងជាជួរត្រង់ ឬមុំចង្ក្រាន ស្ទូងពី ១-៣ដើម ក្នុងមួយគុម្ព
- ស្ទូងឲ្យឬសចូលទៅក្នុងដី ជម្រៅ ១ ទៅ២សង្ទីម៉ែត្រ
- ស្ទូងចន្លោះគុម្ព ប្រែប្រួលទៅតាមប្រភេទដី និងប្រភេទពូជស្រូវ៖
  - ស្រូវស្រាល ចន្លោះពី ១៥ស.ម x ១៥ស.ម

- ស្រូវកណ្តាល ចន្លោះពី ២០ស.ម X ២០ស.ម
- ស្រូវធ្ងន់ ចន្លោះពី ២៥ស.ម X ២៥ស.ម

- រក្សាសំណាប ១-២កណ្តាប់នៅជ្រុងស្រែសម្រាប់ការជួសសន្ទូង។



ស្ទូងជ្រៅនិងបត់ឫស ☒

ស្ទូងរាក់មិនបត់ឫស ☑







ការស្ទូងជាជួរ និងចន្លោះគុម្ពសមស្រប

### ❖ ការស្ទូងស្រូវតាមបច្ចេកទេស ផ្តល់សារៈប្រយោជន៍:

- សន្ទូងទទួលបានជីជាតិ និងពន្លឺថ្ងៃស្មើគ្នា ងាយស្រួលធ្វើស្មៅដោយឧបករណ៍ធ្វើស្មៅ
- សន្ទូងលូតលាស់បានស្មើគ្នាល្អ បែកគុម្ពច្រើន ក្នុងស្រែមានខ្យល់ចេញចូលបានល្អ
- ធន់និងសត្វល្អិត ចំណាយពូជតិច
- បន្សាំបានទៅនឹងការប្រែប្រួលអាកាសធាតុ។



សន្ទូងដុះលូតលាស់ល្អ

## ៣. ការដាំ ឬការព្រោះ

### ❖ ការដាំ ឬការព្រោះគ្រាប់ពូជសើម (ស្រែមានប្រព័ន្ធស្រោចស្រព)

- ភ្ជួរលើកទី២ ត្រៀមដាំដុះបន្ទាប់ ដាក់ជីទ្រាប់បាត រាស់យកស្មៅចេញ កៀរដីស្មើសព្វល្អ
- ត្រាំគ្រាប់ពូជឱ្យដុះពន្លកមាត់ចាប(១យប់ ១ថ្ងៃ) មុនយកទៅដាំឬព្រោះ
- ផ្អាប់គ្រាប់ពូជដុះពន្លកមាត់ចាប១ ថ្ងៃ
- ដីស្រែសើមផុកៗមានទឹកតិចៗ។ ប្រើឧបករណ៍ដាំគ្រាប់ជាជួរ (Drum Seeder) សម្រាប់ប្រើគ្រាប់ពូជសើម ។

- ប្រើពូជ៨០គ.ក្រ ស្រូវពង្រោះរដូវវស្សា ឬ១២០គ.ក្រស្រូវស្រាលពង្រោះ
- អនុវត្តខែកញ្ញា ។ ក្រោយពីអូសដាំ ៧ ថ្ងៃបញ្ចូលទឹក ដើម្បីឲ្យស្រូវដុះល្អឬសរឹងមាំ។
- ប្រើគ្រាប់ពូជសើមមិនធ្វើឱ្យខូចគ្រាប់ពូជដោយរលួយ ជំរុញការលូតលាស់ស្រូវបានលឿន។



គ្រាប់ពូជដុះមាត់ចាប



អូសដាំដោយឧបករណ៍ដាំគ្រាប់



បង្ហើនជម្រៅទឹកតែត្រូវឲ្យមិនលិចកូនសំណាប



មានទឹកស្រូវដុះល្អឬសរឹងមាំ

## ❖ ការដាំ ឬការព្រោះគ្រាប់ពូជស្ងួត (ស្រែគ្មានប្រព័ន្ធស្រោចស្រព រំពឹងទឹកភ្លៀង)

- ភ្ជួរលើកទី២ត្រៀមដាំដុះបន្ទាប់ដាក់ជីទ្រាប់បាត រាស់យកស្មៅចេញ កៀរដីឲ្យស្មើសព្វល្អ
- ពូជ៨០គ.ក្រស្រូវពង្រោះរដូវវស្សា ឬ១២០គ.ក្រសម្រាប់ស្រូវស្រាលពង្រោះ
- ហាលថ្ងៃ ១-២ម៉ោងសិនមុនដាំឬព្រោះ
- ព្រោះគ្រាប់ពូជស្ងួត ឱ្យស្មើនិងសព្វល្អ



ការព្រោះគ្រាប់ស្រូវដោយដៃ



អូសដាំដោយឧបករណ៍ដាំគ្រាប់

- គ្រប់គ្រងទឹក រាស់លប់គ្រាប់ពូជព្រោះ កប់ចូលជ្រៅក្នុងដី រក្សាគ្រាប់ក្នុងដីបានយូរ ដុះបានល្អពេលជួបការរាំងស្ងួតរយៈពេលយូរ ។
- ប្រើម៉ាស៊ីនដាំទំនើប អស់គ្រាប់ពូជតិច  នៃឧបករណ៍ដាំគ្រាប់ជាជួរ (Drum Seeder) ដែរ ប្រើគ្រាប់ស្ងួតពូជ៦០-៨០គីឡូក្រាម ក្នុង១ហិកតា។

# មេរៀនទី ៦: ការគ្រប់គ្រង និងថែទាំ

## ១.គោលបំណង ឲ្យកសិករចេះពី៖

- វិធានការក្នុងការគ្រប់គ្រងបរិមាណទឹកនៅក្នុងវាលស្រែ ដើម្បីការពារទៅនឹងការប្រែប្រួលអាកាសធាតុ
- ការគ្រប់គ្រងស្មៅចង្រៃសត្វល្អិត និងជម្ងឺ
- ដំណាក់កាលនៃការបាចជីបំប៉ន

## ២.ការគ្រប់គ្រងទឹក

- **ស្រូវសន្ទូង៖** រក្សាទឹក ៣-៥ស.ម បន្ទាប់ពីស្ទូងរួចពី ៣-៧ថ្ងៃ
  - បង្កើន២០ស.មសម្រាប់ស្រូវស្រាល
  - ៣០ស.មសម្រាប់ស្រូវកណ្តាលនិងស្រូវធ្ងន់ ដំណាក់កាលស្រូវបែកគុម្ពរហូតដល់ស្រូវទុំ
- **ស្រូវពង្រោះ ឬស្រូវដាំ៖** ស្រូវនឹងដុះល្អពី ៣-៥ថ្ងៃ បើដីស្រែមានសំណើមគ្រប់គ្រាន់
  - រក្សាសំណើមក្នុងស្រែបង្កើនកំពស់ទឹក ៣-៥ស.ម ស្រូវអាយុ៧-១០ថ្ងៃ
  - បន្តរក្សាកំពស់ទឹក២០ស.មស្រូវស្រាល
  - ៣០ស.មស្រូវកណ្តាលនិងស្រូវធ្ងន់ ដំណាក់កាលស្រូវបែកគុម្ពដល់ស្រូវទុំ
- ភ្លៀងមិនគ្រប់គ្រាន់ឬរាំងស្ងួត ត្រូវផ្សើមដីស្រែគ្រាន់តែស្រោចស្រព្វខ្លះៗ បន្តការលូតលាស់របស់ដំណាំស្រូវ
- តំបន់មានភ្លៀងពុំសូវទៀងទាត់ ឆាប់រីងស្ងួតត្រូវ៖
  - ថែទាំភ្លឺឲ្យបានល្អ តែកុំរក្សាទឹកទុកច្រើនពេក (ក្នុងវគ្គលូតលាស់)
  - កំចាត់ស្មៅចង្រៃឲ្យអស់ពីស្រែ
  - ប្រសិនធ្វើទៅបាន គួរជីកស្រះក្នុងស្រែទំហំ ២០ម៉ែត្រ x ១០ម៉ែត្រ




ការថែទាំភ្លឺស្រែ គ្រប់គ្រងទឹក និងកំចាត់ស្មៅ

## ❖ វិធានការ គ្រប់គ្រងបរិមាណទឹកនៅក្នុងវាលស្រែ

- រៀបចំដីស្រែឲ្យរាបស្មើ លើកភ្លឺស្រែខ្ពស់តាមតម្រូវការបរិមាណទឹកទុកក្នុងស្រែ
- ជីកប្រឡាយតូចៗជុំវិញវាលស្រែ និង ជីកស្រះទឹកមួយតូច ស្តុកទឹកទុក
- ទឹកដក់ជាប្រចាំក្នុងស្រែ ឆ្លើយតបសេចក្តីត្រូវការដំណាំស្រូវ បន្ថយធ្វើឱ្យដើមស្រូវ អន់កម្លាំង បាត់បង់ទិន្នផល ទប់ស្កាត់ការដុះលូតលាស់ស្មៅចង្រៃ បង្កើនប្រសិទ្ធភាពដីក្នុងការស្រូបយកជីជាតិ អាសូត។



កូនប្រឡាយរក្សាទឹកដក់ក្នុងស្រែ

## ❖ សារៈប្រយោជន៍ការធ្វើដីឲ្យរាបស្មើ និងលើកភ្លឺស្រែ

- រៀបចំដីស្រែរាបស្មើ ដំណាំស្រូវទទួលបានទឹកស្មើគ្នា
- ភ្លឺស្រែជួយរក្សាទឹកនៅក្នុងស្រែនីមួយៗ
- ភ្លឺស្រែអាចបញ្ចេញបញ្ចូលទឹកបាន (ទឹកហួសពីសេចក្តីត្រូវការប្រសិនបើភ្លៀងច្រើនពេក)



ស្រូវទទួលបានទឹកស្មើល្អ



ការបញ្ចេញបញ្ចូលទឹកក្នុងស្រែ

## ❖ សារៈប្រយោជន៍នៃការជីកប្រឡាយនៅជាប់វាលស្រែ និង/ស្រះទឹកតូច

- ប្រឡាយទឹក និងស្រះទឹកអាចជួយស្តុកទឹក សម្រាប់ប្រើប្រាស់ ប្រសិនបើមានកូនរដូវប្រាំងកើតឡើងនៅក្នុងរដូវវស្សា
- ប្រឡាយទឹកអាចបញ្ចេញបញ្ចូលទឹក ដែលលើសពីសេចក្តីត្រូវការ ចេញពីវាលស្រែ ។



ស្រះទឹក ប្រឡាយការពារកូនរដូវប្រាំង

## ៣.ការគ្រប់គ្រងស្មៅចង្រៃ

- រៀបចំដីស្រែបានស្អាត និងរាបស្មើ
- ធ្វើស្មៅបំផុសដីយ៉ាងតិច២ដង ដោយដៃ ឬប្រើឧបករណ៍ធ្វើស្មៅ (នាគស្រែ)
- ការធ្វើស្មៅបំផុសដីលើកទី១ ក្រោយស្ទូង១៥ថ្ងៃ សំខាន់ ជួយធ្វើឲ្យដីផុស មានខ្យល់ចេញចូល និងធ្វើឲ្យឫសលូតលាស់បានល្អ។
- អនុវត្តពី ២-៣ដង មួយវដ្តជីវិតស្រូវ ពេលស្រូវដុះ ឬស្ទូងរួច ៧-១០ថ្ងៃ និងវគ្គស្រូវបែកគុម្ព និងកកើតកួរ
- ដកពូជស្រូវលាយចេញ ។



ឧបករណ៍ធ្វើស្មៅនាគស្រែ

## ៤.ការគ្រប់គ្រងសត្វល្អិត និងជម្ងឺ

- គ្រប់គ្រងស្មៅចង្រៃ ពិនិត្យវត្តមានសត្វល្អិត និងជម្ងឺធ្វើដំណាលគ្នា
- ស្វែងរកជំនួយបច្ចេកទេស ពីភ្នាក់ងារផ្សព្វផ្សាយកសិកម្មដែលនៅជិតបំផុត ក្នុងករណីមានបញ្ហាធ្ងន់ធ្ងរ។

## ៥. ការបាចជីបំប៉ន

- ប្រើជីធម្មជាតិពុកផុយល្អសម្រាប់បាចបំប៉នដំណាំស្រូវបានដែរ វាជួយកែលំអដី ជួយបង្កើតសំណើមដី និងគម្របដី និងជួយកាត់បន្ថយការបាត់បង់ដី
- ករណីគ្មានការបំផ្លាញពីសត្វល្អិត ជម្ងឺ ឬពុលសារធាតុក្នុងដី ប្រើជីអ៊ុយរ៉េពី ៥០-១០០គ.ក្រ ក្នុង១ហិកតា បាច២ដំណាក់កាលៈ

### ❖ ដំណាក់កាលទី១

- **ស្រូវសន្ទូងៈ** បន្ទាប់ពីស្ទូង១២-១៥ថ្ងៃពូជស្រូវស្រាល និងពី២៥-៣០ថ្ងៃពូជស្រូវកណ្តាលនិងពូជស្រូវធ្ងន់
- **ស្រូវពង្រោះៈ** បន្ទាប់ពីដុះ ២០-២៥ថ្ងៃពូជស្រូវស្រាល  និងពី៣០-៣៥ថ្ងៃពូជស្រូវកណ្តាលនិងពូជស្រូវធ្ងន់
- កម្រិតជីដែលត្រូវប្រើ គឺពី ២៥-៥០គ.ក្រ ក្នុងមួយហិកតា

- បាចពេលមានទឹកក្នុងស្រែជម្រៅពី ៣-៥ស.ម។

❖ **ដំណាក់កាលទី២**

- បាចក្នុងដំណាក់កាលស្រូវបែកគុម្ព ឬដំណាក់កាលស្រូវកកើតកួរ
- ប្រើជី ២៥-៥០គ.ក្រ ក្នុង១ហិកតា
- បាចពេលមានទឹកក្នុងស្រែជម្រៅពី ១០-១៥ស.ម។




ការបាចជីបំប៉ន

❖ **អត្ថប្រយោជន៍នៃការដាក់ជីទ្រាប់បាត**

- ធ្វើឱ្យប្រព័ន្ធឫសស្រូវដុះចាក់ទៅក្រោមបានជ្រៅ និងធានាការរស់បានយូររបស់ដណាំស្រូវនៅពេលជួបគ្រោះរាំងស្ងួតរយៈពេលវែង
- ការប្រើប្រាស់ជីលើសកម្រិត បណ្តាលឲ្យមានការប្រែប្រួលអាកាសធាតុ តាមរយៈការកើនឧស្ម័ននីត្រូហ្សែនដែលមានអំណាចខ្លាំងជាងឧស្ម័នកាបូនិច ដល់ ៣០០ដង ការប្រើប្រាស់ជីត្រឹមត្រូវមានពេលវេលាកំណត់ និងបរិមាណឲ្យបានច្បាស់លាស់ ត្រឹមត្រូវ។

## ៦.គុណសម្បត្តិនៃការភ្ជួរលប់គល់ជញ្ជ្រាំង

- ធ្វើឲ្យដីផុសល្អ
- អាចរក្សាសំណើមក្នុងដីបានយូរ
- ជួយបង្កើនជីជាតិដី
- បន្ថយការចំណាយក្នុងការទិញជីគីមី និង
- ជួយរក្សាបរិស្ថានបានល្អ។



ការភ្ជួរលប់គល់ជញ្ជ្រាំង

# មេរៀនទី ៧: ការប្រមូលផល និងការទុកដាក់គ្រាប់ស្រូវ

## ១.គោលបំណង ឲ្យកសិករចេះពី៖

- បច្ចេកទេសការប្រមូលផលស្រូវ និងការទុកដាក់គ្រាប់ស្រូវ
- អត្ថប្រយោជន៍នៃការគ្រប់គ្រងចំបើង និងជញ្ជ្រាំង

## ៣. ការប្រមូលផល និងការទុកដាក់គ្រាប់ស្រូវ



ប្រមូលផលស្រូវទុំ



ហាលគ្រាប់ស្រូវ

- ស្រូវស្រាលៈ ៩០-១០០ថ្ងៃនៅរដូវប្រាំង ពី១០០-១១០ ថ្ងៃនៅរដូវវស្សា ចាប់ពីថ្ងៃដាំ ដល់ប្រមូលផល (ពូជសែនពិដោរ អ៊ីអ៊ែ៦៦ និងផលសា)
- ស្រូវកណ្តាលៈ ពូជប្រកាន់រដូវ ប្រមូលផលចន្លោះពីចុងខែតុលា ដល់ ចុងខែវិច្ឆិកា
- ស្រូវធ្ងន់ៈ ពូជប្រកាន់រដូវ ប្រមូលផលចន្លោះ ចុងខែធ្នូ ដល់ចុងខែមករា
- គ្រាប់ស្រូវទុំព័ណលឿង៨៥% នៃកួរនីមួយៗ រឹងមិនស្រួយពេលខាំ សំណើមក្នុងគ្រាប់ពី២០-២២%
- បោកបែនបន្ទាប់ច្រូត ហាលគ្រាប់ស្រូវ ២-៣ថ្ងៃ សំណើមគ្រាប់១៤% ស្ងួតល្អ រឹងមិនស្រួយបាក់ពេលខាំ
- ញីបំបែកគ្រាប់ស្រូវ ដោយកែងជើង គ្រាប់ស្រូវដាច់ចេញពីសំបក៨៥-៩៥% ស្ងួតល្អមរក្សាទុកបាន
- ដាក់ក្នុងបាវក្រចៅ ឬ ជង្រុកស្ងួត មានខ្យល់ចេញចូលល្អ ការពារការបំផ្លាញពីសត្វល្អិត (ខ្មូត) កណ្តុរ និងកត់ថ្ងៃ ខែ ប្រមូលផល នៅលើបាវស្រូវ ឬជង្រុក។







ការទុកដាក់គ្រាប់ស្រូវ

## ៤. ការគ្រប់គ្រងចំបើង

- ប្រមូលទុកធ្វើជីកំប៉ុស្ត ចំណីសត្វ គោ ក្របី សម្រាប់ដំណាំ និងប្រើប្រាស់ចាំបាច់នានា
- ជៀសវាងការដុតជញ្រ្ជាំង ចំបើង និងកាកសំណល់ក្នុងស្រែ ចោលនាំឲ្យបាត់បង់ជីជាតិដី បំពុលអាកាសធាតុ និងបរិយាកាសជុំវិញ ធ្វើឲ្យបាត់បង់ជីវចម្រុះក្នុងដី ជាកត្តាសំខាន់ធ្វើឲ្យដីមានជីជាតិ និងមានសំណើមល្អ និងមិនឲ្យហូរច្រោះដីជាតិដី។







ចំបើងជាចំណីគោ ក្របី

ដុតជញ្រ្ជាំង ចំបើង នាំឲ្យបាត់បង់ជីជាតិដី

## ៥.ការលក់ស្រូវ

- លក់ស្រូវសើម  បន្ទាប់ពីប្រមូលផលនៅវាលស្រែ បន្ថយការចំណាយបានលុយភ្លាមៗ និងសួរតម្លៃទីផ្សារឲ្យបានត្រឹមត្រូវ
- លក់ស្រូវស្ងួត ចំណេញច្រើនជាងលក់ស្រូវសើម ពិចារណាទីតាំងទុកដាក់ សម្ភារៈ ពេលវេលា និងតម្រូវការថវិកាមកវិញ
- ការឡើងចុះនៃតម្លៃស្រូវចំណីលើទីផ្សារសេរី មុននឹងលក់ស្រូវសើម ឬស្ងួត
- មុននឹងលក់ គណនាថ្លៃដើមផលិតស្រូវ និងចំណូលបានមកពីការលក់ស្រូវដែលបានផលិត
- ស្វែងរកជំនួយ ឬព័ត៌មានពីមន្ត្រីពាក់ព័ន្ធ ឬវិស័យឯកជន មុនធ្វើការសម្រេចចិត្តលក់ស្រូវ។

# មេរៀនទី៨: ការបញ្ចូលរបៀបថ្មី លើគោលគំនិត អាជីវកម្មកសិកម្មខ្នាតតូច ផ្នែកផលិតកម្មដំណាំស្រូវ

## ១. គោលគំនិតចំបងមុនការផលិត

មានគោលបំណងច្បាស់លាស់ក្នុងការផលិតស្រូវ ទទួលបានផលចំណេញ ឬការខាតបង់។ មុនផលិតត្រូវគិតៈ

### ក. ប្រភេទពូជសម្រាប់ផលិត

- ពូជត្រូវផលិត? ស្រូវស្រាល ស្រូវកណ្ដាល ឬពូជស្រូវធ្ងន់?
- ពូជសមស្របនឹងភូមិសាស្ត្រ (ប្រព័ន្ធក្សេត្របរិស្ថាន) យើងទេ? ធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុទេ?
- ផលិតគោលបំណងធំដើម្បីអ្វី? លក់? ឬហូប? លក់ផង និងហូបផង?
- ជាពូជក្រអូប ឬមិនក្រអូប? ទីផ្សារត្រូវការទេ? លក់តម្លៃប៉ុន្មានក្នុងមួយគីឡូក្រាម? ចំណេញឬទេ?

### ខ. ផ្ទៃដីផលិត

- ប៉ុន្មានហិកតា? ដីផ្ទាល់ខ្លួនប៉ុន្មានហិកតា? ជួលគេបន្ថែម? ប៉ុន្មានហិកតា? តម្លៃក្នុងមួយហិកតា?

### គ.ធនធាន និងប្រភពសម្រាប់ផលិត

- មានប្រភពទឹកស្រោចស្រពទេ? ថ្លៃប៉ុន្មានក្នុងមួយហិកតា?
- មានគ្រាប់ពូជសុទ្ធល្អយកមកផលិតទេ?
- ទិញកន្លែងណាបាន? ថ្លៃមួយគីឡូក្រាម? សរុបថ្លៃពូជ?
- ទិញជី ថ្នាំគីមីកសិកម្មទីណា? ទិញរបៀបយ៉ាងម៉េច? ជឿ ឬឲ្យលុយដល់ដៃ ការប្រាក់ប៉ុន្មាន? ថ្លៃសរុប?
- កម្លាំងពលកម្មគ្រប់គ្រាន់? ខ្វះរកឯណាមាន? ថ្លៃប៉ុន្មានក្នុងមួយថ្ងៃ ឬមួយហិកតា?
- ភ្ជួររាស់ខ្លួនឯង ឬជួលគេ ថ្លៃប៉ុន្មានក្នុងមួយថ្ងៃ ឬមួយហិកតា?
- ទុនផ្ទាល់ខ្លួនប៉ុន្មាន? គ្រប់គ្រាន់ទេ? មិនគ្រប់ខ្ចីពីស្ថាប័នណា ពីអ្នកណា? ការប្រាក់? សរុបអស់ប៉ុន្មាន? ងាយខ្ចីទេ?

### ឃ.ជំនួយបច្ចេកទេស និងទីផ្សារ

- ស្ថាប័នរដ្ឋ ឯកជន ឬអង្គការ នៅជិតអាចផ្ដល់ជំនួយបច្ចេកទេស?
- អ្នកលក់គ្រាប់ស្រូវពូជ លក់ជី ថ្នាំកសិកម្ម ផ្ដល់សេវាបច្ចេកទេសទេ? តាមវិធីណា? គិតលុយ? ងាយស្រួលទំនាក់ទំនងពេលមានបញ្ហាបច្ចេកទេស?
- ទំនាក់ទំនងទីផ្សារស្រូវចំណីជាមុន មុនផលិត? ឈ្មួញទិញស្រូវ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ឬអ្នកលក់ពូជស្រូវ សម្រាប់ការផលិត? ជួយក្នុងការលក់ទេ? កិច្ចសន្យាលក់ជាមួយអ្នកទាំងនោះទេ?
- ដឹកជញ្ជូនគ្រាប់ស្រូវតាមវិធីណាឆ្ពោះទៅកាន់ទីផ្សារ? ឬឈ្មួញមកដឹកដល់ទីកន្លែងផលិត?

# តារាងផែនការអាជីវកម្ម ដំណាំស្រូវ

កាលបរិច្ឆេទសចាប់ផ្ដើមអាជីវកម្ម៖........................................................

**១.ចំណាយថ្លៃវត្ថុធាតុដើម**

| រាយមុខទំនិញ | ឯកតា | ចំនួន | តម្លៃ១ឯកតា(រៀល) | តម្លៃសរុប(រៀល) |
|---|---|---|---|---|
| ពូជស្រូវ | គក្រ | | | |
| ជីគីមី | បាវ | | | |
| ជីកំប៉ុស្ត | គក្រ | | | |
| ប្រេងសាំង | លីត្រ | | | |
| | | | | |
| | | | | |
| សរុបចំណាយថ្លៃវត្ថុធាតុដើម | | | | |

**២.ចំណាយថ្លៃឧបករណ៍/សម្ភារះ**

| រាយមុខឧបករណ៍/សម្ភារះ | ឯកតា | ចំនួន | តម្លៃ១ឯកតា(រៀល) | តម្លៃសរុប(រៀល) |
|---|---|---|---|---|
| កូនពាងទឹក | ចំនួន | | | |
| បាវ | ចំនួន | | | |
| ទ្រុងជីកំប៉ុស្ត | សរុប | | | |
| គោយន្ត | ចំនួន | | | |
| | | | | |
| | | | | |
| សរុបចំណាយថ្លៃឧបករណ៍/សម្ភារះ | | | | |

**សរុបចំណាយទាំងអស់** ................................. + ................................. = .................................

# ប្រតិទិនដាំដុះដំណាំស្រូវ និងទីផ្សារស្រូវចំណី

| ល.រ | សកម្មភាព | រដូវកាលដាំដុះ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ១ | ស្រូវសន្ទូង | | | | | | | | | | | | |
| | ការរៀបចំដី | | | | | | | | | | | | |
| | ការបូមទឹក | | | | | | | | | | | | |
| | ការស្ទូង (ស្រ្តី និង បុរស) | | | | | | | | | | | | |
| ២ | ស្រូវពង្រោះ | | | | | | | | | | | | |
| | ការភ្ជួរលើកទី១ដាស់ដី | | | | | | | | | | | | |
| | ការភ្ជួរលើកទី២ ប្រែដីសម្រាប់ព្រោះស្រូវ | | | | | | | | | | | | |
| | ការព្រោះស្រូវ ឬដាំ | | | | | | | | | | | | |
| ៣ | ប្រមូលផល | | | | | | | | | | | | |
| | ស្រូវស្រាល | | | | | | | | | | | | |
| | ស្រូវកណ្តាល | | | | | | | | | | | | |
| | ស្រូវធ្ងន់ | | | | | | | | | | | | |
| ៤ | ទីផ្សារស្រូវ | | | | | | | | | | | | |
| ៤.១ | ពូជស្រូវលក់បានថ្លៃ និងខែប្រមូលផល | | | | | | | | | | | | |
| | ពូជសែនពិដោរ (ស្រាល) | | | | | | | | | | | | |
| | ពូជផ្ការំដួល (កណ្តាល) | | | | | | | | | | | | |
| | ពូជផ្កាខ្ញី (កណ្តាល) | | | | | | | | | | | | |
| | ពូជផ្កាច័ន្ទសែនសរ (កណ្តាល) | | | | | | | | | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពូជខា៤, ខា៦, នាងខុន (ធ្ងន់) | | | | | | | | | | | | |
| ៤.២ | **ស្រូវចុះថ្លៃ** | | | | | | | | | | | | |
| | ស្រូវស្រាល ស្រូវកណ្តាល ស្រូវធ្ងន់ | | | | | | | | | | | | |

# ប្រតិទិនផ្គត់ផ្គត់ទីផ្សារស្រូវចំណី

| ល.រ | ប្រភពអ្នកទិញ | ប្រតិទិន | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ១ | **ស្រូវចំណី** | | | | | | | | | | | | |
| | អ្នកទិញទុកសម្រាប់ហូបក្នុងស្រុក | | | | | | | | | | | | |
| | ផ្សារក្នុងស្រុកគោលដៅ | | | | | | | | | | | | |
| | រោងម៉ាស៊ីនកិនស្រូវក្នុងស្រុក | | | | | | | | | | | | |
| | ផ្សារទំនើប | | | | | | | | | | | | |
| | ឈ្មួញកណ្តាលទិញលក់ក្នុងស្រុក | | | | | | | | | | | | |
| | ឈ្មួញនាំចេញទៅក្រៅប្រទេស | | | | | | | | | | | | |
| ២ | **ស្រូវពូជ** | | | | | | | | | | | | |
| | សហគមន៍កសិករក្នុងស្រុក | | | | | | | | | | | | |

# តារាង ការវិភាគចំណូលចំណាយ ក្នុងផលិតកម្មដំណាំស្រូវ

| រាយមុខទំនិញ | ឯកតា | ចំនួន | តម្លៃ១ឯកតា(រៀល) | តម្លៃសរុប(រៀល) |
|---|---|---|---|---|
| ១.ចំណាយផលិតកម្ម | | | | |
| ក.ថ្លៃវត្ថុធាតុដើម | | | | |
| ពូជស្រូវ | គក្រ | | | |
| ជីគីមី | បាវ | | | |
| ជីកំប៉ុស្ត | គក្រ | | | |
| ប្រេងសាំង | លីត្រ | | | |
| | | | | |
| | | | | |
| សរុបរងថ្លៃវត្ថុធាតុដើម | | | | |
| ខ.ថ្លៃឧបករណ៍/សម្ភារៈ | | | | |
| កូនពាងទឹក | ចំនួន | | | |
| បាវ | ចំនួន | | | |
| ទ្រុងជីកំប៉ុស្ត | សរុប | | | |
| គោយន្ត (រំលោះ២ឆ្នាំ) | ចំនួន | | | |
| | | | | |
| | | | | |
| សរុបរងថ្លៃឧបករណ៍/សម្ភារៈ | | | | |
| គ.ថ្លៃពលកម្ម | | | | |
| ថ្លៃពលកម្មដកស្ទូង និងថែទាំស្រូវ | នាក់/ថ | | | |
| | | | | |
| | | | | |

| | | | | |
|---|---|---|---|---|
| សរុបរងថ្លៃពលកម្ម | | | | |
| សរុបចំណាយផលិតកម្ម (ថ្លៃវត្ថុធាតុដើម +សម្ភារៈ + ពលកម្ម) | | | | |
| ២.ចំណូល ផលិតផលដែលសម្រេចបាន) | | | | |
| បរិមាណផលស្រូវ | គក្រ | | | |
| | | | | |
| | | | | |
| សរុបរងចំណូលផលិតកម្ម | | | | |
| ៣.ការប្រើប្រាស់ក្នុងគ្រួសារ | | | | |
| កិនជាអង្ករ | គក្រ | | | |
| ចំណីសត្វ (ចុងអង្ករ) | គក្រ | | | |
| | | | | |
| | | | | |
| សរុបរងការប្រើប្រាស់ក្នុងគ្រួសារ | | | | |
| ៤.បរិមាណ ស្រូវ ទុកពូជ | | | | |
| ស្រូវទុកពូជ | គក្រ | | | |
| | | | | |
| | | | | |
| សរុបរងបរិមាណទុកពូជ | | | | |
| សរុបចំណេញ = ចំណូលផលិតកម្ម -ចំណាយផលិតកម្ម | | | | |
| សរុបប្រាក់ចំណេញសុទ្ធ= ចំណេញ -(ប្រើប្រាស់ក្នុងគ្រួសារ + ទុកពូជ) | | | | |

បញ្ហាកើតមានក្នុងផលិតកម្មដំណាំស្រូវ.................................................................................................................................

.......................................................................................................................................................................................

# ឯកសារយោង


១. សៀវភៅកសិករ កម្រងបច្ចេកទេសកសិកម្មល្អៗ ធន់នឹងអាកាសធាតុប្រែប្រួល ខែវិច្ឆិកា ឆ្នាំ២០១៥។ អង្គការ Action Aid, PIN, Save the Children, Oxfam និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

២. គម្រោងបន្សាំនឹងបម្រែបម្រួលអាកាសធាតុសម្រាប់លើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងប្រកបរបរកសិកម្ម MAFF, UNDP, IFAD & gef, 2009។

៣. សៀវភៅបង្កុំបច្ចេកទេស ប្រពលវប្បកម្មដំណាំស្រូវ នាយកដ្ឋាន ដំណាំស្រូវ នៃអគ្គនាយកដ្ឋានកសិកម្ម ខែតុលា ឆ្នាំ ២០១៤។

៤. ព្រឹត្តិបត្រព័ត៌មានកសិករ CARDI Cambodia, ការគ្រប់គ្រងទឹកស្រែ។

៥. ឯកសារ ការជំរុញផលិកម្មស្រូវ និងការនាំអង្ករចេញ របស់រាជរដ្ឋាភិបាល ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ២០១៦។

៦. ផលិតកម្មដំណាំស្រូវ និងការបន្សាំការប្រែប្រួលអាកាសធាតុ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម ឆ្នាំ ២០១៦។


## រៀបរៀង និងបោះពុម្ពលើកទី១ ឆ្នាំ២០១៧ ដោយៈ


នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម ក្រោមមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម(IFAD) និងឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា

អាសយដ្ឋានៈ # ២០០ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា

(ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)

លេខទូរស័ព្ទៈ ០២៣ ២២ ១១ ២០

គេហទំព័រៈWWW.ASPIREKH.ORG